**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ២១១៤ សរ៧

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃ ចំណាយទិញសម្ភារផ្គត់ផ្គង់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ ជូនក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងមហាផ្ទៃ នឹងដាក់ឱ្យដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ចំណាយទិញសម្ភារថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ ជូនក្រសួងមហាផ្ទៃ ។

ក្រសួងមហាផ្ទៃ បានរៀបចំឯកសារដេញថ្លៃ (សៀវភៅបន្ទុក) សម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋានស្ថិតនៅអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៩៧ ៦៦ ៧៧ ៨៥៦) ។

ឯកសារដេញថ្លៃ (សៀវភៅបន្ទុក) ដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មក្រសួងមហាផ្ទៃ យ៉ាងយូរបំផុតត្រឹមវេលាម៉ោង ១០:០០ នាទី ថ្ងៃទី ០៥ ខែ ៤ ឆ្នាំ២០១៧ ។

ការបើកកញ្ចប់ឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅសាលប្រជុំក្រសួងមហាផ្ទៃ វេលាម៉ោង ១០:០០ នាទី ថ្ងៃទី ០៥ ខែ ៤ ឆ្នាំ២០១៧ ។

-ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

-ក្រុមហ៊ុនត្រូវភ្ជាប់ជាមួយនូវឯកសារ ដែលមានចែងក្នុងប្រការ៣ នៃឯកសារដេញថ្លៃនៅពេលដាក់ពាក្យសុំទិញឯកសារដេញថ្លៃ ។

-ចំពោះក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃត្រូវមកទទួល និងដាក់ពាក្យសុំទិញឯកសារនៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋានស្ថិតនៅអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៧ ។ រាល់ពាក្យសុំចូលរួមដេញថ្លៃរបស់បណ្តាក្រុមហ៊ុន នឹងត្រូវដាក់ជូនគណៈកម្មាធិការលទ្ធកម្មពិនិត្យ នឹងវាយតម្លៃអំពីលក្ខណៈសម្បត្តិរបស់ក្រុមហ៊ុន និងសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គលប** មុនលក់ឯកសារដេញថ្លៃ (សៀវភៅបន្ទុក) ជូនក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ និងដាក់ឯកសារដេញថ្លៃតាមកាលបរិច្ឆេទខាងលើ ។

-ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ក្រសួងមហាផ្ទៃ ដើម្បីទិញឯកសារដេញថ្លៃ (សៀវភៅបន្ទុក) និងសាកសួរព័ត៌មាននានាដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ប្រធាន គលប**

**សម្តេចក្រឡាហោម ស ខេង**

ចម្លងជូន ៖
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
"អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ"